# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ....០៦៣......ន. គ. ស/ស.ជ.ណ

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់ពេលវេលាបន្ថែមក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២១ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

យោងតាមសេចក្តីណែនាំលេខ ០១០ ន.គ.ស. ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ស្តីពីការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសេចក្តីជូនដំណឹងលេខ ០៥៩ ន.គ.ស/ស.ជ.ណ. ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២១ តាមប្រព័ន្ធអនឡាញសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ **និយ័តករគណនេយ្យនិងសវនកម្ម** ពិនិត្យឃើញថាអង្គភាពមិនស្វែងរកប្រាក់ចំណេញមួយចំនួនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ មក **និយ័តករគណនេយ្យនិងសវនកម្ម** រួចរាល់ជាស្ថាពរ ប៉ុន្តែអង្គភាពមិនស្វែងរកប្រាក់ចំណេញមួយចំនួនទៀតបានកំពុងជាប់គាំងនៅក្នុងប្រព័ន្ធអនឡាញ (E-Filing for NFPEs) មិនទាន់បញ្ចប់នីតិវិធីបាននៅឡើយ។

ដើម្បីសម្រួលដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលជួបបញ្ហានេះ **ន.គ.ស.** បានសម្រេចផ្តល់ជូនពេលវេលាបន្ថែមដូចតទៅ÷

១. <u>**អង្គភាពមិនរងសវនកម្មឯករាជ្យ**</u>÷ ***រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទី១៥ ខែកញ្ញា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២*** សម្រាប់ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ មក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ (E-Filing for NFPEs)។

២. <u>**អង្គភាពរងសវនកម្មឯករាជ្យ**</u>÷ ***រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២*** សម្រាប់ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលរងសវនកម្មឯករាជ្យរួច មក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ(E-Filing for NFPEs)។

<u>**ការខកខាន ឬការយឺតយ៉ាវមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មក និយ័តករគណនេយ្យនិងសវនកម្មតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ ជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងអាចមានវិធានការរដ្ឋបាលផ្សេងទៀត ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។**</u>

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អង្គភាពមិនស្វែងរកប្រាក់ចំណេញ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ប៊ូ ចារិន**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់ និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111